# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី

# ឯកសារសម្រាប់អ្នកសម្របសម្រួល ស្តីពី យេនឌ័រ និងការប្រែប្រួលអាកាសធាតុ





គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការ
គ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម (NAPA Follow-Up)

ខែសីហា ឆ្នាំ ២០១៣

UNDP
Empowered lives.
Resilient nations.

gef

# មាតិកា


សេចក្តីផ្តើម

មេរៀនទី ១ ៖ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើបុរស និងស្ត្រី

មេរៀនទី ២ ៖ សមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

មេរៀនទី ៣ ៖ តួនាទីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ
ក. តួនាទីយេនឌ័រក្នុងវិស័យកសិកម្ម
ខ. តួនាទីយេនឌ័រក្នុងវិស័យធនធានទឹក

មេរៀនទី ៤ ៖ តម្រូវការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ




# អារម្ភកថា

កាលពីឆ្នាំ២០០៩ គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម ( NAPA Follow-up ) បានដំណើរការអនុវត្តក្នុងខេត្តគោលដៅចំនួន០២ គឺនៅខេត្តក្រចេះនិងខេត្តព្រះវិហារ ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពស្ថាប័នក្នុងការដោះស្រាយកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាលើកកម្ពស់ជីវភាព និងការយល់ដឹងរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ ដែលរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុឲ្យមានលក្ខណៈល្អប្រសើរឡើង។ នៅឆ្នាំ២០១២ គណៈកម្មាធិការយេនឌ័រនិងការប្រែប្រួលអាកាសធាតុ នៃក្រសួងកិច្ចការនារី ដោយបានទទួលការគាំទ្របច្ចេកទេសពីគម្រោង បានរៀបចំសៀវភៅបណ្តុះបណ្តាលដល់គ្រូបង្គោលនៅថ្នាក់ក្រោមជាតិ ស្តីពីការបញ្ជ្រាបយេនឌ័រនិងការប្រែប្រួលអាកាសធាតុ។

សៀវភៅបណ្តុះបណ្តាលនេះ គឺជាឯកសារណែនាំ និងបង្ហាញផ្លូវដល់អ្នកសម្របសម្រួលដើម្បីជាជំនួយក្នុងការបណ្តុះបណ្តាលដល់សហគមន៍ទាក់ទងនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ អ្នកសម្របសម្រួលអាចបំពេញបន្ថែមនូវចំណុចសំខាន់ៗ ស្របតាមស្ថានភាពជាក់ស្តែង និងផ្លាស់ប្តូរទៅតាមតំបន់ផ្សេងៗ ដែលកើតមានការប្រែប្រួលអាកាសធាតុ។ ខ្លឹមសារក្នុងសៀវភៅនេះ បានបញ្ចូលនូវការវិភាគយេនឌ័រនិងការប្រែប្រួលអាកាសធាតុ នៅក្នុងវិស័យកសិកម្មនិងធនធានទឹក ដើម្បីជាបច្ច័យដល់សហគមន៍អំពីវិធីសាស្ត្របន្សាំនិងការប្រែប្រួលអាកាសធាតុ ។

ខ្ញុំសង្ឃឹមថាសៀវភៅបណ្តុះបណ្តាលនេះនឹងក្លាយជាឧបករណ៍មួយដ៏មានសារៈសំខាន់ សម្រាប់គ្រូបង្គោលយកទៅប្រើប្រាស់ក្នុងការសម្របសម្រួលដល់អ្នកពាក់ព័ន្ធ ដើម្បីទទួលបានចំណេះដឹងនិងជំនាញប្រកបដោយប្រសិទ្ធភាព និងការអនុវត្តជាក់ស្តែង។

ជាទីបញ្ចប់ ក្នុងនាមជាប្រធានគណៈកម្មាធិការយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ខ្ញុំសូមកោតសរសើរចំពោះក្រុមការងារយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ក្រសួងកិច្ចការនារី ក្រុមការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមការងារក្រសួងធនធានទឹកនិងឧតុនិយម និងទីប្រឹក្សា UNDP គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹកនិងការប្រកបរបរកសិកម្មដែលបានចងក្រង និងរៀបចំសៀវភៅនេះឡើង។

រាជធានីភ្នំពេញថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣

**អនុរដ្ឋលេខាធិការ**
**និងជាប្រធានគណៈកម្មាធិការ**
**យេនឌ័រ និងការប្រែប្រួលអាកាសធាតុ**

**ប្រាក់ ច័ន្ទណាយ**

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រុមការងារយេនឌ័រនិងការប្រែប្រួលអាកាសធាតុ នៃក្រសួងកិច្ចការនារី ដែលមាន លោកជំទាវ **ប្រាក់ ច័ន្ទណយ** លោកស្រី **ផុតលាង វ៉ាន់នី** លោកស្រី **ជា ហ៊ឹង** លោក **ថេ ឈុនហាក់** លោកស្រី **ចេង ជិនណេត** កញ្ញា **ឆន រដ្ឋា** លោក **សុខ ពិសិដ្ឋ** លោក **សៅ ចន្ទាម៉ាលី** និង លោក **រីម ច័ន្ទរ៉ា** ដែលបានចូលរួមរៀបចំ និងចងក្រងសៀវភៅនេះឡើង។

សូមថ្លែងអំណរគុណ លោក **ហុក គឹមធួន** ប្រធានគម្រោងថ្នាក់ជាតិ អង្គភាពគាំទ្រគម្រោងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក **អ៊ុងដារ៉ា រ័ត្នមុនី** លោក **សួស ពិនរក្ស** លោក **មាស ប៊ុនលី** និងសហការីនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ( UNDP ) ដែលបានជួយពិនិត្យ និងផ្តល់យោបល់លើឯកសារនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកជំទាវរដ្ឋមន្ត្រី លោកជំទាវរដ្ឋលេខាធិការទទួលបន្ទុក លោកជំទាវអគ្គនាយកសមភាពយេនឌ័រនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលតែងតែគាំទ្រ និងផ្តល់នូវអនុសាសន៍ក្នុងរៀបរៀង និងកែលម្អសៀវភៅនេះឲ្យបានគ្រប់ជ្រុងជ្រោយ។

# សេចក្ដីផ្ដើម

បាតុភូតធម្មជាតិនាពេលបច្ចុប្បន្នដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ បាន និងកំពុងគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅតាមជនបទប្រមាណ ៧១% ដែលប្រកបរបរកសិកម្ម (ក្នុងនោះមានស្ត្រី ៥៣% ជាកសិករ) ដូចជា ធ្វើស្រែ ចំការ ចិញ្ចឹមសត្វ នេសាទ និងប្រមូលផល និងអនុផលព្រៃឈើ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើស្ត្រីខុសគ្នា ពីផលប៉ះពាល់មកលើបុរស ដោយសារតែលទ្ធភាពទទួលបានការគ្រប់គ្រងធនធាន និងការចូលរួមរបស់ស្ត្រីមានកម្រិត។ ការប្រែប្រួលអាកាសធាតុក៏បាននាំឲ្យមានវិសមភាពយេនឌ័រកើនឡើង ដែលបញ្ហានេះធ្វើឲ្យស្ត្រីប្រឈមនឹងផលប៉ះបាល់អវិជ្ជមានច្រើនជាងបុរស។ ជាក់ស្ដែងមានការទទួល



ស្គាល់ថា ការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រក្នុងវិស័យកសិកម្មអាចកាត់បន្ថយភាពក្រីក្រ និងគ្រោះអត់ឃ្លាន។ តាមរយៈការប៉ាន់ប្រមាណរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO) ឆ្នាំ២០១១ បានបង្ហាញថាប្រជាពលរដ្ឋ ១០០ លាននាក់ អាចចាកផុតពីភាពក្រក្រី ប្រសិនបើស្ត្រីត្រូវបានគេផ្តល់ឱកាសក្នុងការទទួលបាននិងគ្រប់គ្រងធនធានដូចបុរស ពីព្រោះថាស្ត្រីជាតួអង្គដ៏សំខាន់ក្នុងការផលិត និងផ្តល់ចំណីអាហារ ។ នៅក្នុងរបាយការណ៍នេះក៏បានបង្ហាញថា ការទទួលបានការគ្រប់គ្រងធនធាន និងការសម្រេចចិត្តរបស់ស្ត្រីនៅគ្រប់កម្រិត នៅមានកម្រិតនៅឡើយ។

ក្នុងចំណែកមួយដើម្បីឆ្លើយតបនឹងបញ្ហាយេនឌ័រក្នុងកិច្ចអភិវឌ្ឍន៍និងកម្មវិធីការប្រែប្រួលអាកាសធាតុ គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹកនិងការប្រកបរបរកសិកម្ម (NAPA Follow-Up) សហការជាមួយដៃគូពាក់ព័ន្ធ ដើម្បីរៀបចំឯកសារសម្រាប់បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីទស្សនៈទានជាមូលដ្ឋាន ដែលទាក់ទងនឹងយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ក្នុងទម្រង់ជាផ្ទាំងរូបភាពនិងឯកសារព័ត៌មាន។ លើសពីនេះគម្រោងបានរៀបចំឯកសារណែនាំសម្រាប់អ្នកសម្របសម្រួលមួយទៀត ដើម្បីជាជំនួយការផ្សព្វផ្សាយបង្កើនការយល់ដឹងកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ទាក់ទងនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ឆ្ពោះទៅកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រីនិងកុមារី តាមរយៈការពង្រឹងសមត្ថភាព ការលើកកម្ពស់ការចូលរួមក្នុងការសម្រេច ការជំរុញលើកទឹកចិត្ត និងការផ្តល់ឱកាសក្នុងសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព

# មេរៀនទី ១ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើបុរស និងស្ត្រី

**គោលបំណង៖**

ចុងបញ្ចប់នៃមេរៀនអ្នកចូលរួមអាចកំណត់បាននូវផលប៉ះពាល់មកលើស្ត្រី និងមូលហេតុនៃភាពងាយរងគ្រោះរបស់ស្ត្រី បណ្ដាលមកពីការប្រែប្រួលអាកាសធាតុ។

រយៈពេល ៖ ១ ម៉ោង

វិធីសាស្ត្រ ៖ សំណួរបំផុសគំនិត ការចែករំលែករបស់អ្នកចូលរួម សង្ខេបការពិភាក្សា និងការបង្ហាញរបស់អ្នកសម្របសម្រួល។

ឧបករណ៍ ៖ ផ្ទាំងផ្ទត់រូបភាព ផ្ទាំងរូបភាព រូបថត ។

## ដំណើរការ ៖

អ្នកសម្របសម្រួលចាប់ផ្ដើមដោយសំណួរបំផុសគំនិតដូចខាងក្រោម ៖

- តើអ្វីជាយេនឌ័រ ?
- តើអ្វីជាការប្រែប្រួលអាកាសធាតុ ?
- តើបុរស និងស្ត្រីទទួលរងផលប៉ះពាល់អ្វីខ្លះពីការប្រែប្រួលអាកាសធាតុ ?

.......................................................................................................

.......................................................................................................

.......................................................................................................

អ្នកសម្របសម្រួលកត់ត្រាយោបល់អ្នកចូលរួម ។ អ្នកសម្របសម្រួល អាចរៀបចំយោបល់អ្នកចូលរួមតាមទម្រង់ព័ត៌មានគំរូ អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រវាងបុរស និងស្ត្រី ដូចខាងក្រោម៖

| ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ | បញ្ហាទាក់ទងយេនឌ័រ |
|---|---|
| ខូចខាតដំណាំ និងសត្វពាហនៈ ដែលនាំឲ្យផលិតផលកសិកម្មសម្រាប់ចិញ្ចឹមជីវិតថយចុះ | ស្ត្រីមានតួនាទីក្នុងការធានានូវសន្តិសុខស្បៀងសម្រាប់គ្រួសារ។ |
| អសន្តិសុខស្បៀង | ថយចុះ ឬបាត់បង់ប្រភេទអាហារដែលរកដោយស្ត្រីសម្រាប់ប្រើប្រាស់ក្នុងគ្រួសារជាពិសេស អាហារដែលមានស្រាប់នៅក្នុងសហគមន៍។ |
| ប្រភពទឹករីងស្ងួត និងខ្វះទឹកស្អាតប្រើប្រាស់ | ស្ត្រីកើនឡើងនូវការងារបន្ថែមដើម្បីស្វែងរកទឹក ប្រើប្រាស់ក្នុងសហគមន៍។ |
| កើនបន្ទុកការងារបន្ថែមដើម្បីផលិតស្បៀង និងសកម្មភាពចិញ្ចឹមជីវិត | ជាទូទៅ កុមារី និងស្ត្រីទទួលរាប់រងក្នុងការដងទឹក រកអុស និងជួយសកម្មភាពចិញ្ចឹមជីវិតច្រើន។ ពួកគេកាន់តែពុំមានពេលវេលាគ្រប់គ្រាន់ទៅរៀន។ |
| ការប្រែប្រួលបរិស្ថានទំនងជានាំឲ្យមានចំណាកស្រុក | បុរសភាគច្រើនទំនងជានឹងធ្វើចំណាកស្រុកពេញមួយរដូវ ឬ មួយឆ្នាំ។ ស្ត្រីជាមេគ្រួសារដែលនៅផ្ទះជាអ្នកទីទ័លក្របំផុត។ បន្ទុកការងាររបស់ស្ត្រី កូនរបស់ពួកគាត់ និងចាស់ជរាកើនឡើងដោយសារចំណាកស្រុករបស់បុរស។ |
| ផលប៉ះពាល់បរិស្ថានអាចធ្វើឲ្យមានហានិភ័យនៃជម្ងឺកាន់តែធ្ងន់ធ្ងរ | ស្ត្រីកើនបន្ទុកការងារដោយសារពួកគេមានតួនាទីជាអ្នកថែទាំក្នុងគ្រួសារ។ បាត់បង់រុក្ខជាតិឱសថដែលស្ត្រីរក ឬប្រើប្រាស់។ |
| ការកើនឡើងនៃជម្ងឺបង្កដោយទឹក | ស្ត្រីមានផ្ទៃពោះងាយនឹងមានជម្ងឺបង្កដោយទឹកមិនស្អាត។ ជម្ងឺស្លេកស្លាំងបង្កដោយជម្ងឺគ្រុនចាញ់ ជាហេតុនាំមានមរណៈភាពមាតា។ |

| | |
|---|---|
| ការផុតពូជនៃប្រភេទសត្វ ការប្រែប្រួលប្រភេទសត្វធ្វើកំប៉ុស្តិ៍ ការកាត់ផ្តាច់ទំនាក់ទំនងអតិសុខុមប្រាណ ការផ្លាស់ប្តូរ។<br><br>ការប្រែប្រួលចំនួន និងគុណភាពនៃធនធានធម្មជាតិអាចធ្វើឲ្យផលិតភាពនៃប្រព័ន្ធអេកូឡូស៊ីថយចុះ។ | ដោយពុំមានលទ្ធភាព និងការគ្រប់គ្រងពេញលេញលើធនធានធម្មជាតិ ( ដីធ្លី ទឹក សត្វពាហនៈ ព្រៃឈើ )ស្ត្រីទំនងជាមិនអាចដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបានឡើយ។ ទឹកសម្រាប់ផឹកមានតិច មានន័យថា ស្ត្រីត្រូវប្រឹងប្រែងបន្ថែមទៀត ដើម្បីរកទឹក ស្តារ ការពារ និងបែងចែកទឹក។ ថយចុះធនធានព្រៃឈើដែលស្ត្រីប្រើប្រាស់។ ជារឿយៗ ស្ត្រីពឹងផ្អែកលើដំណាំច្រើនមុខ ( កសិកម្មចម្រុះ ) ដើម្បីតម្រូវទៅតាមការផ្លាស់ប្តូរអាកាសធាតុ ប៉ុន្តែការប្រែប្រួលសីតុណ្ហភាពជាអចិន្ត្រៃយ៍នឹងធ្វើឲ្យកសិកម្មចម្រុះ និងឱសថបុរាណថយចុះ។ |

## ចំណាំ ៖

ព័ត៌មានខាងលើនេះគ្រាន់តែជាព័ត៌មានជំនួយដល់អ្នកសម្របសម្រួលសម្រាប់ដឹកនាំការពិភាក្សា ដូចនេះអ្នកសម្របម្រួលអាចបន្ថែម ឬកែសម្រួលព័ត៌មាន ស្របតាមស្ថានភាពជាក់ស្តែង ។

ដោយភ្ជាប់ជាមួយនឹងយោបល់អ្នកចូលរួម អ្នកសម្របសម្រួលសួរសំណួរបន្ត
" តើស្ត្រីនិងបុរស អ្នកណាទទួលរងផលប៉ះពាល់ខ្លាំងជាង ? មូលហេតុអ្វី ? "





អ្នកសម្របសម្រួលកត់ត្រាយោបល់អ្នកចូលរួម និងបញ្ជាក់ថា ការប្រែប្រួលអាកាសធាតុ លើស្ត្រីខ្លាំងជាងបុរស ។ មូលហេតុសំខាន់ៗមានដូចខាងក្រោម ៖

## មូលហេតុដែលបញ្ជាក់ថាស្ត្រី អាចរងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ខ្លាំងជាងបុរស ៖

១. *អ្នកក្រីក្រភាគច្រើនជាស្ត្រី*
២. *សមត្ថភាព និងការយល់ដឹងទូទៅទាបជាងបុរស*
៣. *ស្ត្រីធ្វើការនៅក្នុងវិស័យដែលងាយទទួលរងផលប៉ះពាល់ ជាពិសេស កសិកម្ម*
៤. *ស្ត្រីទទួលបន្ទុកក្នុងការថែទាំ និងជ្រើសរើសពូជ ប៉ុន្តែស្ត្រីទទួលបានការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យានៅមានកម្រិត*
៥. *ស្ត្រីជាមនុស្សចម្បងក្នុងការផ្តល់ការថែទាំគ្រួសារ និងកូន*
៦. *ស្ត្រីទទួលបានលទ្ធភាពក្នុងការប្រើប្រាស់ធនធាន (ដីធ្លី សត្វពាហនៈ ឧបករណ៍ និងឥណទាន) សេវាកម្ម និងការសម្រេចចិត្តតិចតួច*
៧. *លទ្ធភាពទទួលបានព័ត៌មានរបស់ស្ត្រីមានកម្រិត*
៨. *ការចូលរួមធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីនៅមានកម្រិត*

### សរុប ៖

អ្នកសម្របសម្រួលសង្ខេបឡើងវិញ អំពីការប្រែប្រួលអាកាសធាតុ ពិតជាមានផលប៉ះពាល់មកលើបុរស និងស្ត្រីនៅសហគមន៍ ជាពិសេសស្ត្រី ដោយហេតុថា អ្នកក្រីក្រភាគច្រើនជាស្ត្រី សមត្ថភាព និងការយល់ដឹង និងលទ្ធភាពទទួលបានព័ត៌មានរបស់ស្ត្រីមានកម្រិតបើធៀបជាមួយនឹងបុរស។ល។

# មេរៀនទី ២

# សមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

**គោលបំណង ៖**

ចុងបញ្ចប់នៃមេរៀនអ្នកចូលរួមអាចពន្យល់អំពីសមភាពយេនឌ័រ និងដោះស្រាយវិសមភាពយេនឌ័រ ដើម្បីរួមចំណែកកាត់បន្ថយ ភាពងាយរងគ្រោះរបស់ស្រ្តីបណ្តាលមកពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**រយៈពេល ៖** ៣០ នាទី

**វិធីសាស្រ្ត ៖** សំណួរបំផុសគំនិត ការចែករំលែករបស់អ្នកចូលរួម សង្ខេបការពិភាក្សា និងការបង្ហាញ របស់អ្នកសម្របសម្រួល។

**ឧបករណ៍ ៖** ផ្ទាំងផ្ទត់រូបភាព ផ្ទាំងរូបភាព រូបថត ។

## ដំណើរការ ៖

អ្នកសម្របសម្រួលសួរបំផុសគំនិតនូវអត្ថន័យ ឬខ្លឹមសារនៃពាក្យសមភាពយេនឌ័រ និងកត់ត្រាយោបល់អ្នកចូលរួម។

- តើសមភាពយេនឌ័រជាអ្វី ?

.............................................................................................................

.............................................................................................................

.............................................................................................................

## ព័ត៌មានសម្រាប់អ្នកសម្របសម្រួល

*សមភាពយេនឌ័រ មានន័យថា មនុស្សទាំងអស់ដោយមិនគិតពីភេទ ត្រកូល ជនជាតិ សាសនា អាយុ ស្ថានភាពគ្រួសារ លក្ខណៈរូប ឬរបៀបរស់នៅ ទទួលបាននូវការយកចិត្តទុកដាក់ ឱកាស ការទទួលស្គាល់ ការគោរពសិទ្ធិ និងស្ថានភាពដូចគ្នា។*



### អ្នកសម្របសម្រួលបន្តសួរសំណួរបំផុតគំនិត និងកត់ត្រាយោបល់អ្នកចូលរួមដូចខាងក្រោម ៖

- តើក្នុងសហគមន៍អ្នក មានសមភាពយេនឌ័រដែរឬទេ ? ហេតុអ្វី ?

  ..........................................................................................

  ..........................................................................................

- តើមានបញ្ហាវិសមភាពយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុអ្វីខ្លះ ?

  ..........................................................................................

  ..........................................................................................

- តើត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយបញ្ហារវាងបុរស និងស្ត្រី ក្នុងការប្រែប្រួលអាកាសធាតុ ?

..................................................................................................................................

..................................................................................................................................

## បញ្ជីព័ត៌មានសម្រាប់អ្នកសម្របសម្រួលអំពីដំណោះស្រាយមួយចំនួន ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការបន្សាំការប្រែប្រួលអាកាសធាតុ។

### ព័ត៌មានសម្រាប់អ្នកសម្របសម្រួល

- *ផ្លាស់ប្តូរផ្នត់គំនិតចាស់ដែលយល់ថាស្ត្រីទន់ខ្សោយ*
- *ផ្តល់ឱកាសដល់ស្ត្រីចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងមានតួនាទីជាអ្នកដឹកនាំ*
- *ផ្លាស់ប្តូរជំនឿ និងបង្កើនទំនុកចិត្តរបស់ស្ត្រី*
- *កសាងសមត្ថភាព និងពង្រឹងអំណាចស្ត្រី*
- *ពង្រឹងភាពអង់អាចដល់ស្ត្រី សំដៅលើការលើកទឹកចិត្តស្ត្រី ពង្រឹងសមត្ថភាពស្ត្រី និងបង្កើនលទ្ធភាពស្ត្រី ក្នុងការទទួលបាននូវសេវាឬធនធាននានា ដូចជា ជំនាញជាក់លាក់ និងទុនវិនិយោគសម្រាប់ស្ត្រី ក្នុងសកម្មភាពផលិត និងការបង្កើនសេដ្ឋកិច្ចគ្រួសារ។*
- *បង្កើនការគិតគូរបញ្ហាយេនឌ័រ និងបង្កលក្ខណៈសមស្របជាពិសេសស្ត្រីក្នុងការចូលរួមគ្រប់សកម្មភាពក្នុងកិច្ចអភិវឌ្ឍន៍( ទទួលព័ត៌មាន ទទួលវគ្គបណ្តុះបណ្តាល )*

### សរុប ៖

អ្នកសម្របសម្រួលសង្ខេបឡើងវិញ និងផ្តល់ពាក្យគន្លឹះ អំពីទំនាក់ទំនងសមភាពយេនឌ័រ វិសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ថែមទាំងដំណោះស្រាយមួយចំនួនក្នុងការដោះស្រាយនូវរាល់វិសមភាពទាំងនោះ។

# មេរៀនទី ៣

# តួនាទីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

**គោលបំណង ៖**

ចុងបញ្ចប់នៃមេរៀនអ្នកចូលរួមអាចកំណត់តួនាទីយេនឌ័រ និងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុលើតួនាទីយេនឌ័រ។

**រយៈពេល ៖** ១ម៉ោង ៣០នាទី

**វិធីសាស្ត្រ ៖** សំណួរបំផុសគំនិត ការចែករំលែករបស់អ្នកចូលរួម សង្ខេបការពិភាក្សា និងការបង្ហាញរបស់អ្នកសម្របសម្រួល។

**ឧបករណ៍ ៖** ផ្ទាំងផ្ទត់រូបភាព ផ្ទាំងរូបភាព រូបថត ។

## ដំណើរការ ៖

**អ្នកសម្របសម្រួលសួរសំណួរបំផុសគំនិត និងកត់ត្រាយោបល់អ្នកចូលរួម ៖**

- តើបុរស និងស្ត្រីមានតួនាទីអ្វីខ្លះក្នុងសហគមន៍ និងគ្រួសារ ? ?

.........................................................................................

.........................................................................................

.........................................................................................

.........................................................................................

.........................................................................................

## ព័ត៌មានសម្រាប់អ្នកសម្របសម្រួល

- *កសិកម្ម ៖ ការជ្រើសរើសពូជ ការរៀបចំដី ការសាបព្រួស ដកស្ទូង ការថែទាំ ការច្រូតកាត់ ការបោកបែន ការដឹកជញ្ជូន ការទុកដាក់ពូជ ការទុកហូប ការកែច្នៃ និងការលក់ផលិតផល។ល។*
- *ការចិញ្ចឹមសត្វ ៖ ការជ្រើសរើសពូជ ការធ្វើទ្រុង ការថែទាំ (ការផ្តល់ទឹកចំណី អនាម័យ...) ការលក់ដូរ ។ល។*
- *ធនធានទឹក ៖ ការរកទឹកសម្រាប់ផឹក ដាំស្ល ជុសលាង អនាម័យ និងចិញ្ចឹមសត្វពាហនៈតូចៗ ប្រើប្រាស់ និងគ្រប់គ្រងទឹកសម្រាប់ស្រោចស្រព ឬកសិដ្ឋានចិញ្ចឹមសត្វ និងសម្រាប់ឧស្សាហកម្ម (Fisher ២០០៦);*
- *ធនធានធម្មជាតិ ៖ រកអុស បោចវល្លិ បេះផ្សិតផ្លែឈើព្រៃឱសថបុរាណ...*
- តើការប្រែប្រួលអាកាសធាតុប៉ះពាលលើបុរស និងស្ត្រីដូចគ្នាដែរឬទេ ? ហេតុអ្វី ?

### ព័ត៌មានសម្រាប់អ្នកសម្របសម្រួល

ប្រសិនបើចំណុចខាងក្រោមនេះ រវាងបុរស និងស្ត្រីមិនដូចគ្នា ពួកគាត់ក៏ទទួលរងនូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមិនដូចគ្នាដែរ។

- *កម្រិតពឹងផ្អែកលើធនធានសម្រាប់ការរស់នៅប្រចាំថ្ងៃ*
- *ទំនាក់ទំនងមិនស្មើភាពនៅក្នុងការប្រើប្រាស់ និងការគ្រប់គ្រង*
- *ការបែងចែកផលប្រយោជន៍*
- *ភាពជាម្ចាស់ និងសិទ្ធិលើធនធាន*
- *ការយល់ដឹងផ្សេងគ្នាអំពីធនធាន និងបញ្ហារបស់វា*

- តើការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់លើការប្រកបមុខរបរចំពោះបុរស និងស្ត្រី ដូចម្តេច?

.....................................................................................................

.....................................................................................................

.....................................................................................................

## តារាងព័ត៌មានសម្រាប់អ្នកសម្របសម្រួលអំពីផលប៉ះពាល់ខុសៗគ្នា លើតួនាទីរបស់បុរស និងស្ត្រី។

| ស្ត្រី | បុរស | ទំនាក់ទំនងនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ |
|---|---|---|
| នៅផ្ទះមើលថែទាំកូន និងចាស់ជរា ព្រមទាំងអ្នកជម្ងឺជាសមាជិកក្នុងគ្រួសារ | ធ្វើចំណាកស្រុកដើម្បីទទួលបានឱកាសរកប្រាក់ចំណូល | លទ្ធភាពរបស់បុរសធ្វើចំណាកស្រុកស្វែងរកឱកាសរកប្រាក់ចំណូល ធ្វើឲ្យពួកគាត់កាន់តែងាយស្រួលក្នុងការដោះស្រាយវិបត្តិ និងអាចជួយឧបត្ថម្ភដល់គ្រួសារទាំងមូល។ ប៉ុន្តែការធ្វើចំណាកស្រុករបស់បុរស តែងតែបង្កើនការងារបន្ថែមទៀតដល់ស្ត្រី ដោយសារពួកគេ (ស្ត្រី) នៅផ្ទះ គ្រប់គ្រងផ្ទះសម្បែងលើសពីការងារប្រចាំ។ វាថែមទាំងបង្កើននូវហានិភ័យលើស្ត្រី ដូចជា អំពើហិង្សាក្នុងគ្រួសារ និងការឆ្លងមេរោគអេដស៍ HIV ។ |
| ដាំដំណាំនៅជុំវិញផ្ទះ និងចិញ្ចឹមសត្វ | ដាំដំណាំសម្រាប់លក់ និងចិញ្ចឹមសត្វ | ទាំងដំណាំ និងសត្វពាហនៈត្រូវរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់សន្តិសុខស្បៀង ឬផ្គត់ផ្គង់ក្នុងគ្រួសារ។ បុរសតែងតែទាមទារនូវដីដែលមានជីជាតិជាងសម្រាប់ដាំដុះដំណាំដែលទីផ្សារត្រូវការ ចំណែកស្ត្រីដាំដុះដំណាំតាមគ្រួសារលើដីដែលមិនសូវមានជីជាតិ។ |

| | | |
|---|---|---|
| ទទួលរ៉ាប់រងក្នុងការរៀបចំ និងទុកដាក់អាហារ | ទទួលរ៉ាប់រងលក់ដូរ ផលិតផល (មានតម្លៃ) និងសត្វពាហនៈ | ការប្រែប្រួលអាកាសធាតុមានទំនាក់ទំនងជាមួយការរៀបចំ និងទុកដាក់អាហារ (ទឹកសម្រាប់ដាំស្ល និងភាពងាយរងគ្រោះចំពោះការទុកដាក់ អាហារដោយសារហេតុការធ្ងន់ធ្ងរ ដូចជា ព្យុះកំបុតត្បូង និងទឹកជំនន់)។ ការប្រមូលផលអាចនឹងត្រូវថយចុះ ឬបំផ្លាញដោយអាកាសធាតុប្រែប្រួល ទឹកជំនន់ ឬគ្រោះរាំងស្ងួត។ ហេតុការណ៍ទាំងនេះប៉ះពាល់ដល់ តម្លៃទីផ្សារ និងផលិតផលនៅសល់សម្រាប់លក់ ដែលដាក់សម្ពាធលើទាំងស្ត្រី និងបុរសក្នុងការរកប្រភពចំណូលដទៃទៀត និងបន្ថយការចំណាយចាំបាច់ (ឧទាហរណ៍ ថ្លៃសាលារៀន)។ អំឡុងពេលខ្វះខាត ស្ត្រីតែងតែរំពឹងផ្តល់អាហារដល់សមាជិកគ្រួសាររបស់ខ្លួនមុន។ |
| មានចំណូលទាប និងច្រើនពឹងផ្អែកលើការសន្សំសំចៃ | មានចំណូលខ្ពស់ និងមានកម្មសិទ្ធិលក់ដីធ្លី និងទ្រព្យដទៃទៀត | ជាទូទៅ បុរសមានលុយ និងទ្រព្យដទៃទៀតច្រើនជាងស្ត្រី។ ការសន្សំ របស់បុរសផ្តល់ឲ្យសម្រាប់តែនៅពេលលំបាក និងទ្រព្យដែលធ្វើឲ្យពួកគេងាយស្រួលក្នុងការប្រកបរបរជាជម្រើសដទៃទៀតសម្រាប់ចិញ្ចឹមជីវិត។ |
| មានការអប់រំ និងទទួលព័ត៌មានតិចតួច | មានការអប់រំ និងទទួលព័ត៌មានច្រើន | ការគ្រប់គ្រងហានិភ័យអាកាសធាតុចំពោះផលិតកម្មកសិកម្មតម្រូវឲ្យមានព័ត៌មានជំនាញ និងបច្ចេកវិជ្ជាថ្មី ដូចជា ការព្យាករណ៍រដូវកាល ការវិភាគហានិភ័យ និងការធ្វើកសិកម្មតាមបែបសន្សំសំចៃទឹក។ បុរសទំនងជាមានលទ្ធភាពច្រើនក្នុងការប្រើប្រាស់ធនធានទាំងនេះ ចំណេះដឹង និងអំណាចប្រើប្រាស់ធនធានទាំងនោះ ដូច្នេះត្រូវបានបំពាក់បំប៉នយ៉ាងប្រសើរសម្រាប់បន្សាំ។ ព័ត៌មានថ្មី និងចាស់អាចមានសារៈសំខាន់ក្នុងការបន្សាំ។ |

| | | |
|---|---|---|
| មានអំណាចតិចតួចលើហិរញ្ញវត្ថុគ្រួសារ និងទ្រព្យដទៃទៀត | មានអំណាចច្រើនលើហិរញ្ញវត្ថុគ្រួសារ និងទ្រព្យដទៃទៀត | ដោយពុំមានអំណាចសម្រេចចិត្តលើធនធានក្នុងគ្រួសារ និងហិរញ្ញវត្ថុ សមត្ថភាពរបស់ស្ត្រីក្នុងការគ្រប់គ្រងហានិភ័យនៅមានកម្រិត ឧទាហរណ៍ ការធ្វើកសិកម្មដំណាំ ការទុកដាក់អាហារ ឬគ្រាប់ពូជ ឬការសន្សំ។ |
| មានការចូលរួមមិនពេញលេញក្នុងនយោបាយសហគមន៍ | មានការចូលរួមយ៉ាងសម្បើមក្នុងនយោបាយសហគមន៍ និងធ្វើសេចក្តីសម្រេច | បុរសទំនងជាមានឥទ្ធិពលច្រើនលើគោលនយោបាយលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងកម្មវិធី ជាងស្ត្រី។ |
| ប្រឈមនឹងការដាក់កម្រិតដោយវប្បធម៌/បម្រាមមិនឲ្យដើរហើរ | ប្រឈមនឹងការដាក់កម្រិតវប្បធម៌តិចតួចក្នុងការដើរហើរ | ការដើរហើរ គឺជាកត្តាសំខាន់មួយក្នុងការទទួលព័ត៌មាន និងសេវានានា។ វាមានសារៈសំខាន់ផងដែរសម្រាប់គេចចេញពីគ្រោះថ្នាក់បង្កដោយលក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរ។ ស្ត្រីមានហានិភ័យខ្ពស់ពីហេតុការណ៍ទាំងនោះ ប៉ុន្តែបុរស មានតួនាទីក្លាហាន អាចនឹងមានហានិភ័យផងដែរ។ |

## ចំណាំ ៖

ព័ត៌មានទាំងនេះអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងនីមួយៗ។

## សរុប ៖

អ្នកសម្របសម្រួលសង្ខេប និងផ្តល់ពាក្យគន្លឹះមួយចំនួនឡើងវិញ អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់បុរស និងស្ត្រី។

# មេរៀនទី ៤

# តម្រូវការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

**គោលបំណង ៖**

ចុងបញ្ចប់នៃមេរៀនអ្នកចូលរួមអាចកំណត់តម្រូវការយេនឌ័រ និងដំណោះស្រាយដើម្បីដោះស្រាយបញ្ហាប្រឈម ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

**រយៈពេល ៖** ១ម៉ោង

**វិធីសាស្ត្រ ៖** សំណួរបំផុសគំនិត ការចែករំលែករបស់អ្នកចូលរួម សង្ខេបការពិភាក្សា និងការបង្ហាញរបស់អ្នកសម្របសម្រួល។

**ឧបករណ៍ ៖** ផ្ទាំងផ្ទត់រូបភាព ផ្ទាំងរូបភាព រូបថត ។

## ដំណើរការ ៖

អ្នកសម្របសម្រួល សួរសំណួរបំផុសគំនិត និងកត់ត្រាយោបល់អ្នកចូលរួម ៖

- តើបុរស និងស្ត្រីមានតម្រូវការអ្វីខ្លះ ?

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

.......................................................................................................

# តារាងព័ត៌មានសម្រាប់អ្នកសម្របសម្រួលអំពីតម្រូវការរបស់បុរស និងស្ត្រី។

## ព័ត៌មានសម្រាប់អ្នកសម្របសម្រួល

- *តម្រូវការចំពោះមុខ ៖ កើតចេញពីស្ថានភាពជាក់ស្តែងដែលស្ត្រី និងបុរស បានជួបប្រទះ ក្នុងការអនុវត្តការងារដែលកំណត់ដោយសង្គម ក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា ចំណី អាហារ ទឹក ជម្រក ។ល។*
- *តម្រូវការជាយុទ្ធសាស្ត្រ ៖ កើតចេញមកពីបញ្ហាឋានៈ តួនាទី និងសិទ្ធិអំណាចក្នុងសង្គម។ ស្ត្រីភាគច្រើនមានឋានៈ តួនាទី និងសិទ្ធិអំណាចតិចតួច ពិសេសការធ្វើសេចក្តីសម្រេចនៅក្នុងសង្គម។*



- ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ តើត្រូវមានតម្រូវការយេនឌ័រអ្វីខ្លះ ?

..........................................................................................................

..........................................................................................................

## តារាងព័ត៌មានសម្រាប់អ្នកសម្របសម្រួលអំពីតម្រូវការដែលបណ្តាលមកពីបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ ។

### ព័ត៌មានសម្រាប់អ្នកសម្របសម្រួល

- *តម្រូវការយេនឌ័រដែលត្រូវដោះស្រាយ ៖ សិទ្ធិសុខភាព អាហារ ទឹក វប្បធម៌ ការចូលរួម ការរើសអើង និងវិសមភាពក្នុងសង្គមជាដើម។*
- *សមត្ថភាព និងតម្រូវការទាក់ទងដែលត្រូវដោះស្រាយរួមមាន ៖*

  ១. *ការផ្តល់ និងទទួលបានព័ត៌មាន*

  ២. *ភាពអង់អាចក្នុងការធ្វើសេចក្តីសម្រេច*

  ៣. *បង្កើនចំណេះដឹង និងសមត្ថភាព*

  ៤. *ការទទួលបាន និងគ្រប់គ្រងទ្រព្យសម្បត្តិ និងធនធាន (ទាំងថវិកា និងសម្ភារ)*

  ៥. *ធនធានសង្គម*

  ៦. *ការបណ្តុះបណ្តាល*

  ៧. *បច្ចេកវិទ្យា និងសិទ្ធិសម្រេចជ្រើសរើសបច្ចេកវិទ្យាដែលត្រូវទទួលយក។*

**សរុប ៖**

អ្នកសម្របសម្រួលសង្ខេប និងផ្តល់ពាក្យគន្លឹះមួយចំនួនឡើងវិញ អំពីតម្រូវការរបស់បុរស និងស្ត្រី ដើម្បីផ្តល់យុទ្ធសាស្ត្រដោះស្រាយ ឬឆ្លើយតប។

## ឯកសារពិគ្រោះ ៖

- ការប្រែប្រួលអាកាសធាតុ និងយន្តការអភិវឌ្ឍន៍ស្អាត (ក្រសួងបរិស្ថាន ឆ្នាំ២០០៤)
- គេហទំព័រ htttp://www.preventionweb.net ឆ្នាំ២០១១
- ក្រសួងបរិស្ថាន ឆ្នាំ២០១០
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១០
- គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ខែសីហា ឆ្នាំ២០១០
- The Little REDD Book, Global Canopy Programme (GCP) ឆ្នាំ២០០៨
- UNEP ឆ្នាំ២០០៨
- ក្រសួងកិច្ចការនារី ឆ្នាំ២០១១
- ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) ឆ្នាំ២០០៧





## ទំនាក់ទំនង


លោកជំទាវ ប្រាក់ ច័ន្ទណាយ
អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី/
ប្រធានគណៈកម្មាធិការយេនឌ័រ
និងការប្រែប្រួលអាកាសធាតុ
អាគារលេខ៣ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ +៨៥៥ (០)២៣ ២១៦ ៧០៤
+៨៥៥ (០)១២ ៨២២ ៦៥៨
អ៊ីម៉ែល ៖ channay.prak@yahoo.com

លោក ហុក គឹមធួន
ប្រធានគម្រោងថ្នាក់ជាតិ
អង្គភាពគាំទ្រគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់
និងនេសាទ (MAFF PSU)
អាគារលេខ២០០ មហាវិថីព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ +៨៥៥ (០)២៣ ៩៩៣ ៣៤២
អ៊ីម៉ែល ៖ kimthourn@gmail.com